ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៤៥៩ ព.ណ.ន.អជ..

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យអនុវត្តវិធានដាក់លាក់សម្រាប់ផលិតផល តាមប្រព័ន្ធសុខដុម HS 2022 ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន ផលិតករ និងអ្នកនាំចេញទាំងអស់ឱ្យបានជ្រាបថា គណៈកម្មាធិការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បានបញ្ចប់នីតិវិធីនិងអនុម័តជាផ្លូវការលើការផ្ទេរបញ្ជីវិធានដាក់លាក់សម្រាប់ផលិតផល (Product Specific Rules-PSR) ពីប្រព័ន្ធសុខដុម AHTN 2017 ទៅ AHTN 2022 និងបានឯកភាពដាក់ឱ្យអនុវត្តបញ្ជី PSR នេះ តាមប្រព័ន្ធសុខដុម HS 2022។

ក្នុងន័យនេះ សម្រាប់ការនាំចេញទំនិញដែលមានទិសដៅទៅកាន់បណ្តាប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) នឹងត្រូវអនុវត្តបញ្ជី PSR តាមប្រព័ន្ធសុខដុម HS 2022 **ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦** តទៅ។

ចំពោះព័ត៌មានលម្អិត និងឯកសារគតិយុត្តពាក់ព័ន្ធអាចទាញយកបានតាម QR Code ខាងក្រោម។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកប្រព័ន្ធទូរស័ព្ទសាធារណៈក្រសួងពាណិជ្ជកម្ម លេខ១២៦៦។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ផលិតករ និងអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យបានគត់មត់។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *

សូមស្កេនដើម្បី
ទាញយកឯកសារ

សូមស្កេនដើម្បី
ទទួលបានព័ត៌មានពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469